# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ
## “ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣”

**ថ្ងៃអង្គារ ១២ កើត ឆ្នាំជូត ទោស័ក ព២០២០ខែកញ្ញា ឆ្នាំ ២៩ត្រូវនឹងថ្ងៃទី ២៥៦៤ .ស.**

**សណ្ឋាគារភ្នំពេញ**

- គោរពអង្គពិធីទាំងមូល
- **លោកស្រីបណ្ឌិត** KHIN Cho ទីប្រឹក្សាព័ត៌មានយុទ្ធសាស្ត្រ អង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- លោក John Eyres ប្រធានការិយាល័យសុខភាពសាធារណៈ និងអប់រំនៃអង្គការ USAID ប្រចាំប្រទេសកម្ពុជា
- ឯកឧត្តម លោកជំទាវគណៈអធិបតី
- ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-រាជធានីភ្នំពេញ
- ឯកឧត្តម លោកជំទាវ លោក-លោកស្រីតំណាងក្រសួង-ស្ថាប័ន អង្គការជាតិ និងអន្តរជាតិទាំងអស់ជាទីរាប់អាន!

ថ្ងៃនេះក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាអធិបតី ក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ “**ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣**”។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី**

“**ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣**” ដែលនឹងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលបន្តិចទៀតនេះ គឺជាសមិទ្ធិផលថ្មីមួយទៀត ដែលបង្ហាញពីសុឆន្ទៈនយោបាយដ៏មោះមុតរបស់

រាជរដ្ឋាភិបាលកម្ពុជាឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥-៩៥-៩៥ និងការបញ្ចប់ការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍នៅត្រឹមឆ្នាំ២០២៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមគាំទ្រយ៉ាងសកម្ម ទូលំទូលាយ និងពហុវិស័យពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន អ្នកផ្ទុកមេរោគអេដស៍ ក្រុមប្រជាជនគន្លឹះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែល ជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មទាំងផ្នែកបច្ចេកទេស និងថវិកាក្នុងការរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិមួយនេះឱ្យលេចចេញជារូបរាងឡើងស្របតាមការអំពាវនាវរបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យមានការចូលរួមជាចលនាជាតិតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបដើម្បីបញ្ចប់មេរោគអេដស៍ និងជំងឺអេដស៍នៅឆ្នាំ២០២៥ ជាពិសេសគឺឈរលើគោលការណ៍ "**ការចូលរួមប្រកបដោយថាមវ័ន្តនៃភាគីពាក់ព័ន្ធ**" ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងនាមជាសកម្មជននៅគ្រប់លំដាប់ថ្នាក់ទាំងអស់ យើងគួរតែមានមោទនភាព ចំពោះវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធិផលប្រកបដោយជោគជ័យ ដែលកម្ពុជាយើងទទួលបានកន្លងមកក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការអនុវត្តនូវ "**គោលការណ៍បីមួយ**" ប្រកបដោយប្រសិទ្ធខ្ពស់ រហូតមានការទទួលស្គាល់ជាអន្តរជាតិ ជាពិសេសពីស្ថាប័នអង្គការសហប្រជាជាតិទទួលបន្ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍នៅឆ្នាំ២០១៧ ថាជាប្រទេសមួយក្នុងចំណោមប្រទេសទាំង៧ នៅលើសកលលោកមានដូចជា ចក្រភពអង់គ្លេស អ៊ីស្លង់ ដាណឺម៉ាក ស៊ុយអ៊ែត សឹង្ហបុរី និងបុតស្វាណា ដែលអាចសម្រេចបាននូវគោលដៅ ៩០-៩០-៩០ មុនកាលកំណត់។

### ឯកឧត្តម លោកជំទាវ លោក-លោកស្រី

នៅត្រឹមឆ្នាំ២០២០ នេះកម្ពុជាបានសម្រេចរួចទៅហើយនូវគោលដៅ ៩០-៩០-៩០ ដូច្នេះកម្ពុជាត្រូវបន្តដំណើរឆ្ពោះទៅរកគោលដៅថ្មីមួយទៀតគឺ ៩៥-៩៥-៩៥ នៅត្រឹមឆ្នាំ២០២៥ អាស្រ័យហេតុនេះហើយបានជាយើងរួមគ្នាក្នុងការបន្តរៀបចំនូវផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់យើងបន្តទៀត ដើម្បីប្រើប្រាស់ជា មគ្គុទេសក៏តម្រង់ផ្លូវមួយដែលមានរយៈពេលវែង មានលក្ខណៈគ្រប់ជ្រុងជ្រោយ គ្របដណ្តប់លើគ្រប់វិស័យ និងប្រកបដោយបរិយាប័ន្ន និងជាពិសេស ដោយបានគោរពយ៉ាងខ្ជាប់ខ្ជួន ទៅនឹងផែនការយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីប្រកាសនៃការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍និងជំងឺអេដស៍របស់រាជរដ្ឋាភិបាល តាមរយៈសេចក្តីជូន

ជំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥នេះ គឺបានរៀបចំឡើងក្រោមចក្ខុវិស័យរួមមួយដើម្បីបញ្ចប់មេរោគអេដស៍ និងជំងឺអេដស៍នៅឆ្នាំ២០២៥ ដោយមិនទុកឱ្យប្រជាពលរដ្ឋកម្ពុជាណាម្នាក់រងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ក្នុងក្តីសង្ឃឹមដ៏មុតមាំ កសាងមនុស្សជាតិជំនាន់ថ្មីមួយដែលគ្មានមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានគោលបំណងជាក់លាក់ចំនួន៤គឺ៖

១. ទីមួយ: ជានាឱ្យមានការបញ្ចូលអន្តរាគមន៍ប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ តាមរយៈវិធីសាស្ត្រសម្របសម្រួល និងពហុវិស័យ។
២. ទីពីរ: សមាហរណកម្មកម្មវិធីបង្ការ ថែទាំ និងការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល ដើម្បីទទួលបាននូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងចីរភាព។
៣. ទីបី: បង្កើនលទ្ធភាពទទួលបាននូវយន្តការគាំពារសង្គម និងសេវាសង្គម សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ និង
៤. ទីបួន: បង្កើនថវិកាជាតិ និងអន្តរជាតិគាំទ្រដល់ការផ្តល់សេវាសំខាន់ៗដែលអនុវត្តដោយអង្គការសង្គមស៊ីវិលដើម្បីពង្រឹងចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍។

ជាមួយនឹងគោលបំណងនីមួយៗ គឺយុទ្ធសាស្ត្រនេះក៏បានរំលេច និងបញ្ជាក់ច្បាស់ពីសកម្មភាពគន្លឹះដែលត្រូវយកទៅអនុវត្តក្នុងការធានាឱ្យបាននូវអត្រាគ្របដណ្តប់ទៅលើក្រុមគោលដៅ ទៅលើភូមិសាស្ត្រ និងទៅលើសេវាបានគ្រប់ជ្រុងជ្រោយថែមទៀតផង។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ឥឡូវនេះយើងទាំងអស់គ្នាមាន **"ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣"** ដូច្នេះយើងត្រូវតែបន្តរួមគ្នាក្នុងការចលនាប្រើប្រាស់ផែនការឱ្យអស់លទ្ធភាព តាមរយៈការបំប្លែងផែនការនេះ ឱ្យចេញទៅជាសកម្មភាពស្របទៅនឹងអាណត្តិការងាររបស់ក្រសួង ស្ថាប័នជាសមាជិកទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល សម្រាប់យកទៅអនុវត្តនៅទូទាំងប្រទេស។

យើងបានដឹងទាំងអស់គ្នាហើយថាបច្ចុប្បន្ននេះ និងទៅអនាគតពិភពលោក រួមទាំងកម្ពុជាផងដែរ កំពុងតែប្រឈមមុខខ្ពស់ទៅនឹងបញ្ហាជំងឺកូវីដ-១៩ ដែលបាន និងកំពុងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសេដ្ឋកិច្ចជាតិ និងពិភពលោក និងប៉ះពាល់ផងដែរមកលើថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រនេះ។ អាស្រ័យហេតុ ខ្ញុំសូមអំពាវនាវឱ្យមានការចូលរួមយ៉ាងទូលំទូលាយ និងពហុវិស័យក្នុងការចលនាការគាំទ្រធនធាន និងការប្រើប្រាស់ធនធានដែលមានកម្រិតនេះឱ្យបានចំគោលដៅ និងឱ្យមានប្រសិទ្ធភាពខ្ពស់ ដែលក្នុងនោះ

គឺមិនអាចខ្វះបាននូវវេទិកាសម្របសម្រួលពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានឡើយ។

ដូច្នេះ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ទោះបីយើងប្រឈមនឹងបញ្ហាធនធាននៅក្នុងអំឡុងពេលដែលមានបញ្ហាកូវីដ-១៩ នេះក៏ដោយ ក៏យើងនៅតែអាចសម្រេចបាននៅគោលដៅ ៩៥-៩៥-៩៥ ជាក់ជាមិនខាន ប្រសិនបើយើងធ្វើការឆ្លើយតបរួមគ្នាក្រោមស្ថាប័នសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងប្រព័ន្ធតាមដាន និងវាយតម្លៃតែមួយ។

ជាក់ស្តែងក្នុងឆ្នាំ២០១៩នេះ អង្គការ UNAIDS បានប្រកាសទទួលស្គាល់ហើយថាកម្ពុជា សម្រេចបាន **៨៤- ១០០-៩៦** នៃគោលដៅ **៩៥-៩៥-៩៥** ដែលរាជរដ្ឋាភិបាលបានកំណត់ថានឹងត្រូវសម្រេចឱ្យបាននៅឆ្នាំ២០២៥។ ដូចនេះ ការងារដែលសំខាន់នាពេលនេះ គឺយើងទាំងអស់គ្នា ត្រូវប្រឹងប្រែងពុះពាររួមគ្នារកគ្រប់មធ្យោបាយដើម្បីសម្រេចគោលដៅ **៩៥** ទី១ ឱ្យបាន**១០០%** ឬ**៩៥%** តាមការកំណត់។

ម្យ៉ាងទៀត ទិសដៅយើងនាពេលនេះ គឺត្រូវឈានទៅសម្រេចឱ្យបាននូវគោលដៅអ្នកឆ្លងថ្មី ក្នុងមួយឆ្នាំមិនឱ្យលើសពី ៣៦០នាក់ ឬ ១នាក់ ក្នុង១ថ្ងៃ និងអ្នកស្លាប់ដោយសារជំងឺអេដស៍ មិនឱ្យលើសពី១.០០០នាក់ ឬ ៣នាក់ ក្នុង១ថ្ងៃ។

លើសពីនេះទៀត យើងត្រូវបន្តនាំគ្នាសម្រេចឱ្យបានគោលបំណងទាំងបួននៃផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ តាមរយៈការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវ ស.ជ.ណ ២១៣ ដែលបានកំណត់វិធានការទាំង៦ ដូចខាងក្រោម៖

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្តល់កញ្ចប់ថវិកាដោយឡែកសម្រាប់អនុវត្តការបញ្ជ្រាបការងារប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់។

២ក្រសួងសុខាភិបាល និងក្រសួងផែនការ រៀបចំកំណត់ . និងចាត់ទុកថា អ្នកផ្ទុកមេរោគអេដស៍ ជាក្រុមប្រជាជនងាយរងគ្រោះដែលត្រូវទទួលបានប័ណ្ណសមធម៌ ដើម្បីធានាដល់ការទទួលបានសេវាថែទាំសុខភាព និងការគាំពារសង្គម។

៣ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច . និងហិរញ្ញវត្ថុ សហការកែសម្រួល រៀបចំវិធាន និងនីតិវិធីក្នុងការផ្តល់កញ្ចប់ថវិកាដើម្បីឱ្យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពមានថវិកាផ្ទាល់សម្រាប់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

៤ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច . និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលស្គាល់តួនាទីសំខាន់របស់អង្គការសង្គមស៊ីវិលក្នុងការ

ឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ និងបន្តគាំទ្រឱ្យមានការចូលរួមបន្តទៀតតាមរយៈការផ្តល់មូលនិធិពីរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាជាតិ។

៥. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិសិក្សាលំហថវិកា ដើម្បីធានាការអនុវត្តការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាល ក្នុងការបញ្ចប់បញ្ហាអេដស៍ នៅក្នុងឆ្នាំ២០២៥។

៦ក្រសួងសុខាភិបាល . បន្តពង្រឹងធនធានមនុស្ស ការធ្វើលទ្ធកម្ម ការផ្គត់ផ្គង់ ឱសថបរិក្ខារ និងប្រព័ន្ធព័ត៌មាន ដើម្បីបញ្ជ្រាបការឆ្លើយតបការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាព និងធានាចីរភាព។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ ជូនចំពោះសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ អង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំនូវគម្រោងផែនការយុទ្ធសាស្ត្រនេះ ក្រោមការរៀបចំ និងសម្របសម្រួលពីអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាពិសេសជូនចំពោះអង្គការ UNAIDS និងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (ហៅកាត់ USAID) និងផែនការបន្ទាន់សម្រាប់ការបន្ថយជំងឺអេដស៍របស់ប្រធានាធិបតីសហរដ្ឋអាមេរិក (ហៅកាត់ PEPFAR) តាមរយៈកម្មវិធី HP+ និងមូលនិធិសកល ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការជាតិ អន្តរជាតិ ដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយនាពេលនេះ សូមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "**ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ ២០១៩-២០២៣**" ចាប់ពីពេលនេះតទៅ។

*សូមអរគុណ !*